រក 67/16→12/9/2016

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៧-៩-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៩១៦/៨១៣ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជាចង្កោមគ្រួសារ ដល់គ្រួសារអ្នកស្រី **លី ឈិន យូស៊ីវ** (LEE CHEN YU-HSIU) ៧៨៤៩

១០-៩-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៩១៦/៨១៤ ស្ដីពី ការតែងតាំង លោក **ម៉ាត់ សា** ជាឧកញ៉ាឃ្នុរមេដឹកនាំសាសនាឥស្លាមក្រុមកនអ៊ីមុំសាន់ ៧៨៥០


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១២-៩-២០១៦ -អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ស្ដីពី ការទទួលស្គាល់វិទ្យាស្ថានអាជីវកម្មអន្តរជាតិ ៧៨៥១

១២-៩-២០១៦ -អនុក្រឹត្យលេខ ១៨៥ អនក្រ.បក ស្ដីពី ការដំឡើងកម្រិតបណ្ដុះបណ្ដាល និងប្រែក្លាយឈ្មោះមជ្ឈមណ្ឌលអភិវឌ្ឍន៍ មុខជំនាញកម្ពុជា-ថៃ ទៅជា វិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ ៧៨៥៤

១៣-៩-២០១៦ -អនុក្រឹត្យលេខ ១៨៦ អនក្រ.បក ស្ដីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ៧៨៥៨

១៣-៩-២០១៦ -អនុក្រឹត្យលេខ ១៨៧ អនក្រ.បក ស្ដីពី ការបង្កើតតំបន់អភិរក្សទឹកសាបបឹងព្រែកទប់ ៧៨៧៨

០៩-៩-២០១៦ -អនុក្រឹត្យលេខ ៩២៩ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧៨៨២

០៩-៩-២០១៦ -អនុក្រឹត្យលេខ ៩៣០ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧៩១៣

០៩-៩-២០១៦ -អនុក្រឹត្យលេខ ៩៣១ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៧៩២១


### ២~សេចក្ដីសម្រេច


១៣-៩-២០១៦ -សេចក្ដីសម្រេចលេខ ១០០ សសរ ស្ដីពី ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិផែនការយុទ្ធសាស្ត្រ ស្ថិតិកសិកម្ម និងជនបទនៅព្រះរាជាណាចក្រកម្ពុជា ៧៩៤៥

១៤-៩-២០១៦ -សេចក្ដីសម្រេចលេខ ១០១ សសរ ស្ដីពី ការតែងតាំងប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៧៩៤៩

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ១៥-៩-២០១៦ | -សេចក្តីសម្រេច ០៥១ សហវ ស្តីពី ការបង្កើតក្រុមការងាររៀបចំមគ្គុទេសក៏គ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៧៩៥១ |
| ១៥-៩-២០១៦ | - សេចក្តីសម្រេច ០៥២ សហវ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ ស្ថិតក្រោមក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ៧៩៥៤ |


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម


| | | |
|---|---|---|
| ១៨-៧-២០១៦ | -ប្រកាសលេខ ៤០៨ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី.ភី. ខេមបូឌា ចំកាត់ បង្កើតសាខារោងចក្រ ផលិតចំណីសត្វ | ៧៩៥៦ |
| ១៨-៧-២០១៦ | -ប្រកាសលេខ ៤០៩ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេហ្គ្រីខលឈ័រ អិនធីឌី (ខេមបូឌា) បង្កើតរោងចក្រ កែច្នៃដំឡូងមី | ៧៩៥៩ |
| ១៨-៧-២០១៦ | -ប្រកាសលេខ ៤១០ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខសមិកស៍ អយល៍ ខេមបូឌា បង្កើតរោងចក្រ ផលិតប្រេងរំអិល | ៧៩៦២ |
| ១៨-៧-២០១៦ | -ប្រកាសលេខ ៤១១ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត បង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៧៩៦៥ |
| ១៨-៧-២០១៦ | -ប្រកាសលេខ ៤១២ ឧស.កឧ.ប្រក.០៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្មាត ភី ហ្គាមេន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៧៩៦៨ |

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៦/ ៨១៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មជាចង្កោមគ្រួសារ ដល់គ្រួសារអ្នកស្រី **លី ឈិន យូស៊ីវ** ដែលមានសមាជិក:

១- អ្នកស្រី **លី ឈិន យូស៊ីវ** (LEE CHEN YU-HSIU) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិនូវែលសេឡង់ កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៥៤ នៅទីក្រុងការស៊ុង សាធារណរដ្ឋចិន (ជាប្រពន្ធ)។

២- លោក **លី មីុងឈី** (LEE MING-CHIH) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៥៣ នៅខេត្តតៃវ៉ាន់ សាធារណរដ្ឋចិន (ជាប្តី)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រលៈ ១៦០៩.៤២៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៦*

លេខៈ ៨១៤ ស.ណ
សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

នស/រកត/០៩១៦/ ៨១៤

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ត្រាស់បង្គាប់**

**តែងតាំង លោក ម៉ាត់ សា**

**ជា**

**ឧកញ៉ាឃ្លូរ**
**មេដឹកនាំសាសនាឥស្លាម ក្រុមកនអ៊ីម៉ុំសាន់**

ប្រគល់ភារកិច្ចជូនឧកញ៉ាឃ្លូរ រៀបចំរចនាសម្ព័ន្ធ តាមព្រះវិហារ
ក្រុមកនអ៊ីម៉ុំសាន់ នៅព្រះរាជាណាចក្រកម្ពុជា។

**នរោត្តម សីហមុនី**

៣៦៧-១៦០៩: ៨២៧
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៦*

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
លេខ ៩៤៤/១៦ រ.ចច
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៦
សម្តេចចៅហ្វាវាំងវរវៀងជ័យ អធិបតីស្រីធរ្មាធិការ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានអាជីវកម្មអន្តរជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

- បានឃើញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ១៧៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការទទួលស្គាល់វិទ្យាស្ថានអាជីវកម្មអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១ .-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឯកជនមួយ ដែលមានឈ្មោះថា «វិទ្យាស្ថានអាជីវកម្មអន្តរជាតិ» ឈ្មោះជាភាសាអង់គ្លេស «International Business Institute» សរសេរកាត់ជាភាសាខ្មែរ «វ.អ.អ.» និងសរសេរកាត់ជាភាសាអង់គ្លេស «I.B.I»។

**មាត្រា២ .-**

វិទ្យាស្ថានអាជីវកម្មអន្តរជាតិ មានទីតាំងស្ថិតនៅដីឡូត៍លេខ៣២ ផ្លូវលេខ១៩៨៦ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ វិទ្យាស្ថាននេះស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៣ .-**

វិទ្យាស្ថានអាជីវកម្មអន្តរជាតិ មានភារកិច្ចធ្វើការបណ្តុះបណ្តាល៖

- កម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម ០១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ សិក្សារយៈពេល១ ២ និង ៣ឆ្នាំ ដែលមានយ៉ាងតិច ៣០ក្រេឌីត (សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ដែលមានយ៉ាងតិច ៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស ឬសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ដែលមានយ៉ាងតិច ១២០ក្រេឌីត។

នៅថ្ងៃអនាគត វិទ្យាស្ថាននេះអាចបើកសាខា ដេប៉ាតឺម៉ង់ មហាវិទ្យាល័យ ដំឡើងកម្រិត ប្តូរទីតាំងឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៤ .-**

វិទ្យាស្ថានអាជីវកម្មអន្តរជាតិ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃវិទ្យាស្ថានអាជីវកម្មអន្តរជាតិ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥ .-**

នាយកវិទ្យាស្ថានអាជីវកម្មអន្តរជាតិ មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានអាជីវកម្មអន្តរជាតិ និងធានាឱ្យមានសុវត្ថិភាព និងសណ្ដាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសសិស្សឱ្យចូលរៀន ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- គោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលបានកំណត់អំពីសកម្មភាពនៃការធានាគុណភាពតាមវិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ជូននាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈឱ្យបានទៀងទាត់តាមការកំណត់។

**មាត្រា៦ .-**

សិស្ស-និស្សិតដែលបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះ ត្រូវផ្ដល់ដោយវិទ្យាស្ថានអាជីវកម្មអន្តរជាតិ ដែលមានការទទួលស្គាល់ពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថានបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

**មាត្រា៧ .-**

ប្រកាសលេខ១៧៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្ដីពីការទទួលស្គាល់វិទ្យាស្ថានអាជីវកម្មអន្តរជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកវិទ្យាស្ថានអាជីវកម្មអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងកម្រិតបណ្តុះបណ្តាល និងប្រែក្លាយឈ្មោះមជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ ទៅជា វិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញសារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- បានឃើញប្រកាសលេខ១៨០ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការដំឡើងកម្រិតបណ្តុះបណ្តាលមជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១.-**

ត្រូវបានប្រែក្លាយ មជ្ឈមណ្ឌលអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ ទៅជា «វិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ» ឈ្មោះជាភាសាអង់គ្លេស «Cambodian-Thai Skills Development Institute» សរសេរជាអក្សរកាត់ជាភាសាខ្មែរ «វ.អ.ក.ថ.» និងសរសេរជាអក្សរកាត់ជាភាសាអង់គ្លេស «CTSDI»។

វិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ ស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងនៅផ្លូវអូរដឹម-កប់ស្រូវ ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

**មាត្រា ២.-**

វិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ មានភារកិច្ចធ្វើការបណ្តុះបណ្តាល៖
- កម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម ១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ ២ និង៣ សិក្សារយៈពេល ១ឆ្នាំ ២ឆ្នាំ និង ៣ឆ្នាំ ដែលមានយ៉ាងតិច ៣០ក្រេឌីត (សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស បរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ដែលមានយ៉ាងតិច ៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ដែលមានយ៉ាងតិច ១២០ក្រេឌីត។

**មាត្រា ៣.-**

ចំពោះមុខ វិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ មានរចនាសម្ព័ន្ធដូចខាងក្រោម ៖
- ការិយាល័យរដ្ឋបាល និងបុគ្គលិក
- ការិយាល័យហិរញ្ញវត្ថុ និងផែនការ
- ការិយាល័យទំនាក់ទំនងឧស្សាហកម្ម
- ការិយាល័យធានាគុណភាព
- ការិយាល័យបណ្តុះបណ្តាល
- ការិយាល័យអភិវឌ្ឍន៍កម្មវិធីសិក្សា
- ដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា
- ដេប៉ាតឺម៉ង់អគ្គិសនី
- ដេប៉ាតឺម៉ង់សំណង់ស៊ីវិល

- ដេប៉ាតឺម៉ង់រថយន្ត
- ដេប៉ាតឺម៉ង់អក្សរសាស្ត្រអង់គ្លេស

នៅថ្ងៃអនាគត វិទ្យាស្ថានអាចបង្កើតការិយាល័យ ដេប៉ាតឺម៉ង់ ឬឯកទេសដទៃទៀត ឬដំឡើងកម្រិតបណ្តុះបណ្តាល ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៤.-**

លក្ខខណ្ឌទទួលសិស្ស-និស្សិតឱ្យចូលរៀន ៖

- កម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ៖ បេក្ខជនជាសិក្ខាកាម សិស្ស-និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១៖ បេក្ខជនបានរៀនចប់ថ្នាក់ទី៩ នៃមធ្យមសិក្សាបឋមភូមិ ឬវិញ្ញាបនបត្រស្ថានចម្លងបន្តជំនាញ ឬវិញ្ញាបនបត្រដែលមានតម្លៃស្មើ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ២៖ បេក្ខជនដែលមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ៣៖ បេក្ខជនដែលមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ២
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស បរិញ្ញាបត្ររង៖ បេក្ខជនដែលប្រឡងជាប់ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ៣ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ៖ បេក្ខជនមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស បរិញ្ញាបត្ររង ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស-និស្សិតឱ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

**មាត្រា ៥.-**

នាយកនៃវិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ មានបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមាននាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

រចនាសម្ព័ន្ធរបស់វិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៦.-**

វិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ កាន់កាប់ និងប្រើប្រាស់ប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវឧបត្ថម្ភដោយថវិកាជាតិសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានគណនេយ្យដោយឡែក។

**មាត្រា ៧.-**

សិស្ស-និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាន ហើយទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា។

វិញ្ញាបនបត្រ ឬសញ្ញាបត្រដែលផ្តល់ឱ្យដោយវិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ នឹងត្រូវទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថានបានបំពេញ និងអនុវត្តតាម គោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ នាយកវិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៧ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

**សម្រេច**

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះកំណត់អំពីឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងមួករបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ សម្រាប់ប្រើប្រាស់បំពេញការងារចុះអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ សរសេរជាអក្សរកាត់ថា **ម.អ.ទ.**។

## ជំពូកទី២

## ឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងមួក

### ផ្នែកទី១

### ឯកសណ្ឋាន

**មាត្រា២ ._**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ឯកសណ្ឋានបុរស

- អាវដៃខ្លីពណ៌ខៀវទឹកប៊ិចចាស់ កឱប ថ្នេរឱប ប៉ូលស្មាសងខាង សម្រុងជើងអាវត្រង់ស្មើ ឆែកចំហៀងមានហោប៉ៅលើពីរ គម្របរាងស្លឹកពោធិ៍បិទដោយឡេវធម្មតា
- អាវដៃវែងពណ៌ខៀវទឹកប៊ិចចាស់កបើកថ្នេរឱប ប៉ូលស្មាសងខាង សម្រុងជើងអាវត្រង់ស្មើ ឆែកពីក្រោយសងខាងហើយមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើដេរបត់ផ្នត់កណ្តាល មានគម្របរាងចតុកោណកែងបិទដោយឡេវរូបព្រះសង្ការពណ៌មាស ឬប្រាក់ តាមឋានានុក្រម ហោប៉ៅខាងក្រោមដេរគ្មានផ្នត់កណ្តាល មានគម្របរាងចតុកោណកែងបិទដោយឡេវដូចហោប៉ៅខាងលើ អាវដៃវែងនេះពាក់ពីខាងក្រៅ ហើយចំពោះអាវខាងក្នុងគឺអាវសឺមីពណ៌សដៃវែង ក្រវ៉ាត់កពណ៌ខៀវទឹកប៊ិចចាស់
- ខោជើងវែងពណ៌ខៀវទឹកប៊ិចចាស់ ដេរថ្នេរបង្កប់ ចង្កេះត ជីបក្លីខាងមុខពីរសងខាង មានហោប៉ៅចំនួនបី ហោប៉ៅខាងក្រោយមួយដេរបង្កប់ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរ
- ស្បែកជើងឃ្លុបពណ៌ខ្មៅ មានកែង កខ្លី ចងខ្សែនិងស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រមទំហំក្បាលខ្សែក្រវ៉ាត់មានទទឹង៣៥ម.ម. បណ្តោយ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៅចំកណ្តាល។

ខ- ឯកសណ្ឋាននារី

- អាវម៉ូដដូចបុរស ប៉ុន្តែកអាវមានរាងកអាវរបស់ស្ត្រី មានពណ៌ខៀវទឹកប៊ិចចាស់

- ខោម៉ូដដូចបុរស ប៉ុន្តែគ្មានហោប៉ៅក្រោយ មានពណ៌ខៀវទឹកប៊ិចចាស់ ឬសំពត់ហ្សីបពណ៌ខៀវទឹកប៊ិចចាស់ សម្រុងក្រោមជង្គង់ ផែកក្រោយ រូតពីក្រោយ
- ស្បែកជើងពណ៌ខ្មៅឃ្លុបមុខឃ្លុបក្រោយ មានកែងនិងស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រមទំហំក្បាលខ្សែក្រវ៉ាត់មានទទឹង៣៥ម.ម. បណ្តោយ៦៥ម.ម. ដែលមានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៅចំកណ្តាល
- ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១។

## ផ្នែកទី២
## សញ្ញាសម្គាល់

**មាត្រា៣.-**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានសញ្ញាសម្គាល់ដែលត្រូវពាក់នៅលើដៃអាវខាងស្តាំ។ សញ្ញាសម្គាល់នេះធ្វើអំពីក្រណាត់ក្រាស់ពណ៌ផ្ទៃមេឃរាងជារង្វង់មានអង្កត់ផ្ចិតប្រវែង៨ស.ម. មានរូបផែនដី រំលេចដោយអក្សរ "**ម.អ.ទ**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់សវិទ្យុនៅចំកណ្តាល ព័ទ្ធជុំវិញដោយពាក់កណ្តាលខាងលើជាអក្សរខ្មែរ "មន្ត្រីអធិការកិច្ចទូរគមនាគមន៍" និងពាក់កណ្តាលខាងក្រោមជាអក្សរអង់គ្លេស"Inspector of Telecoms" ខណ្ឌដោយសញ្ញាផ្កាយចំនួនពីរ។ សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី២។

**មាត្រា៤.-**

សញ្ញាសម្គាល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាសញ្ញាធ្វើពីលោហធាតុ រាងសំប៉ែត ភ្ជាប់ដោយបន្ទះស្បែកសម្រាប់ព្យួរលើហោប៉ៅអាវខាងស្តាំ ទំហំរង្វង់អង្កត់ផ្ចិត៦០ម.ម.។ សញ្ញាសម្គាល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ព្យួរលើហោប៉ៅរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៣។

**មាត្រា៥.-**

សញ្ញាសម្គាល់សម្រាប់ពាក់ជាប់ចុងកអាវ ធ្វើពីលោហធាតុរាងសំប៉ែតពណ៌មាស ឬពណ៌ប្រាក់ តាមឋានានុក្រមជាសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ទំហំ១៥ម.ម.។ សញ្ញាសម្គាល់សម្រាប់ពាក់ជាប់ចុងកអាវរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៤។

**មាត្រា៦.-**

ស្លាកសម្គាល់ឈ្មោះមន្ត្រីអធិការកិច្ចទូរគមនាគមន៍ សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្តាំមានរាងចតុកោណកែងដែលមាន បណ្តោយប្រវែង៨,៥ស.ម. ទទឹង២,៥ស.ម. សរសេរអក្សរពណ៌ទឹកមាស ឬទឹកប្រាក់តាមឋានានុក្រមមានផ្ទៃពណ៌ខៀវចាស់ មានសរសេរគោត្តនាមនិងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងមុខងារមន្ត្រីរាជការជាអក្សរខ្មែរពីក្រោម។ ស្លាកសម្គាល់ឈ្មោះរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៥។/.

## ផ្នែកទី៣
## សញ្ញាសក្តិ

**មាត្រា៧ ._**

សញ្ញាសក្តិស្មា មានបាតក្រោមប្រវែង៦(ប្រាំមួយ)សង់ទីម៉ែត្រ បណ្តោយពីលើបាតក្រោមប្រវែង១៣(ដប់បី)សង់ទីម៉ែត្រ និងមានទទឹងមុខកាត់ផ្នែកខាងលើប្រវែង៤,៧(បួនក្បៀសប្រាំពីរ)សង់ទីម៉ែត្រ មានរាងកោងជាមុំទាល។

សញ្ញាសក្តិស្មា មាន៧(ប្រាំពីរ)ថ្នាក់ តាមមុខតំណែងរបស់មន្ត្រីរាជការដូចខាងក្រោម៖

១- **ថ្នាក់អគ្គាធិការនិងអគ្គនាយក**: មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ មានអក្សរ "**ម.អ.ឆ.**"ពណ៌មាសនៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិភ្ជាប់ដោយឡេវរូបព្រះសង្ខារពណ៌មាស នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សិរីឡុហើយនៅចន្លោះអក្សរ "**ម.អ.ឆ.**" និងរូបនិមិត្តសញ្ញាហ្វ្រេកង់សិរីឡុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌មាសចំនួនបួន។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៦។

២- **ថ្នាក់អគ្គាធិការរងនិងអគ្គនាយករង**: មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញមានអក្សរ "**ម.អ.ឆ.**"ពណ៌មាសនៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិ ភ្ជាប់ដោយឡេវរូបព្រះសង្ខារពណ៌មាស នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សិរីឡុ ហើយនៅចន្លោះអក្សរ "**ម.អ.ឆ.**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់សិរីឡុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌មាសចំនួនបី។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៧។

៣-**ថ្នាក់អធិការនិងប្រធាននាយកដ្ឋាន**: មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញមានអក្សរ"**ម.អ.ឆ.**"ពណ៌មាសនៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិភ្ជាប់ដោយឡេវរូបព្រះសង្ខារពណ៌មាសនៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សិរីឡុ ហើយនៅចន្លោះមានអក្សរ "**ម.អ.ឆ.**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់សិរីឡុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌មាសចំនួនពីរ។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៨។

៤- **ថ្នាក់អធិការរង អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរប.ទ រាជធានី ខេត្ត**: មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញ មានអក្សរ"**ម.អ.ឆ.**"ពណ៌មាសនៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិ ភ្ជាប់ដោយឡេវរូបព្រះសង្ខារពណ៌មាស នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សិរីឡុ ហើយនៅចន្លោះអក្សរ"**ម.អ.ឆ.**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់សិរីឡុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌មាសចំនួនមួយ។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី៩។

៥- **ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរប.ទ រាជធានី ខេត្ត**: មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ មានអក្សរ "**ម.អ.ឆ.**"ពណ៌ប្រាក់នៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិ ភ្ជាប់ដោយឡេវរូបព្រះសង្ខារពណ៌ប្រាក់ នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់សិរីឡុ ហើយនៅចន្លោះអក្សរ "**ម.អ.ឆ.**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់សិរីឡុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និង

និងទូរគមនាគមន៍រាងផ្កាយពណ៌ប្រាក់ចំនួនបី។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១០។

៦- **ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យប.ទ រាជធានី ខេត្ត:** មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ មានអក្សរ "**ម.អ.ទ.**"ពណ៌ប្រាក់នៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ផ្នែកខាងលើចុងនៃសញ្ញាសក្តិ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌ប្រាក់ នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់ស៍វិទ្យុ ហើយនៅចន្លោះអក្សរ"**ម.អ.ទ.**"និងរូបនិមិត្តសញ្ញាហ្វ្រេកង់ស៍វិទ្យុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌ប្រាក់ចំនួនពីរ។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១១។

៧- **ថ្នាក់មន្ត្រី:** មានផ្ទៃពណ៌ខៀវទឹកប៊ិចចាស់ ក្បាច់ភ្ញីទេសពណ៌ប្រាក់ព័ទ្ធជុំវិញ មានអក្សរ "**ម.អ.ទ.**" ពណ៌ប្រាក់នៅផ្នែកខាងគល់នៃសញ្ញាសក្តិ។ ផ្នែកខាងលើចុងនៃសញ្ញាសក្តិ ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌ប្រាក់ នៅផ្នែកកណ្តាលនៃសញ្ញាសក្តិមានរូបនិមិត្តសញ្ញាហ្វ្រេកង់ស៍វិទ្យុ ហើយនៅចន្លោះអក្សរ "**ម.អ.ទ.**" និងរូបនិមិត្តសញ្ញាហ្វ្រេកង់ស៍វិទ្យុ មានរូបសញ្ញាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រាងផ្កាយពណ៌ប្រាក់ចំនួនមួយ។ សញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១២។

## ផ្នែកទី៤
## មួក

**មាត្រា៨ ...**

មួកកាស្កេត មាន៥(ប្រាំ)ថ្នាក់៖

១ -**ថ្នាក់អគ្គាធិការនិងអគ្គនាយក:** មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើជើងមួកពណ៌ខ្មៅ មានភ្ជាប់រូបព្រះសង្ការពណ៌មាស ទំហំកម្ពស់៧៨ម.ម. ទទឹង៦៨ម.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការមានខ្សែធ្លាក់វិញខ្ចាតធំពណ៌មាសពីលើជើងមួកពណ៌ខ្មៅព្រមទាំងនៅខាងចុងខ្សែធ្លាក់វិញទាំងសងខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌មាស ខាងក្រោមខ្សែធ្លាក់វិញផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ជាខ្សែសយពណ៌មាសដោយម៉ាស៊ីនកុំព្យូទ័រ ទម្រង់ស្លែងក្របីធំពេញក្បាំង ៥សន្លឹក ដល់ជើងមួក។

២- **ថ្នាក់អគ្គាធិការរងនិងអគ្គនាយករង:** មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើជើងមួកពណ៌ខ្មៅ មានភ្ជាប់រូបព្រះសង្ការពណ៌មាស ទំហំកម្ពស់៧៨ម.ម. ទទឹង៦៨ម.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការមានខ្សែធ្លាក់វិញខ្ចាតតូចពណ៌មាសពីលើជើងមួកពណ៌ខ្មៅព្រមទាំងនៅខាងចុងខ្សែធ្លាក់វិញទាំងសងខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌មាស ខាងក្រោមខ្សែធ្លាក់វិញផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេស ប៉ាក់ជាខ្សែសយពណ៌មាសដោយម៉ាស៊ីនកុំព្យូទ័រ ទម្រង់ស្លែងក្របីធំពេញក្បាំង ៥សន្លឹក ដល់ជើងមួក។

៣- **ថ្នាក់អធិការ ប្រធាននាយកដ្ឋាន អធិការរង អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីរប.ទ រាជធានី ខេត្ត:** មួកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើជើងមួកពណ៌ខ្មៅ មានភ្ជាប់រូបព្រះសង្ការពណ៌មាស ទំហំកម្ពស់៧៨ម.ម. ទទឹង៦៨ម.ម. ផ្នែកខាងក្រោមនៃជើងមួក និងក្រោមព្រះសង្ការមានខ្សែធ្លាក់វិញខ្ចាតតូចពណ៌មាសពី

ពីលើជើងម្ចុកពណ៌ខ្មៅ ព្រមទាំងនៅខាងចុងខ្សែធ្វាក់វិញទាំងសងខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌មាស ខាងក្រោមខ្សែធ្វាក់វិញផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ជាខ្សែសយពណ៌មាសដោយម៉ាស៊ីនកុំព្យូទ័រ ទម្រង់ស្នែងក្របីធំពាក់កណ្តាលក្បាំង ៣សន្លឹក។

**៤- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានមន្ទីរប.ទ រាជធានី ខេត្ត អនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យប.ទ រាជធានី ខេត្ត:** ម្ចុកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើជើងម្ចុកពណ៌ខ្មៅ មានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ ទំហំកម្ពស់៧៨ម.ម. ទទឹង៦៨ម.ម. ផ្នែកខាងក្រោមនៃជើងម្ចុកនិងក្រោមព្រះសង្ការមានខ្សែធ្វាក់វិញខ្នាតតូចពណ៌ប្រាក់ពីលើជើងម្ចុកពណ៌ខ្មៅ ព្រមទាំងនៅខាងចុងខ្សែធ្វាក់វិញទាំងសងខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌ប្រាក់ ខាងក្រោមខ្សែធ្វាក់វិញផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើក្បាំងមានប៉ានក្បាច់ភ្ញីទេសប៉ាក់ជាខ្សែសយពណ៌ប្រាក់ដោយម៉ាស៊ីនកុំព្យូទ័រទម្រង់ស្នែងក្របីធំពាក់កណ្តាលក្បាំង ៣សន្លឹក។

**៥- ថ្នាក់មន្ត្រី:** ម្ចុកកាស្កេតធ្វើពីក្រណាត់ពណ៌ដូចអាវ ផ្នែកខាងមុខលើជើងម្ចុកពណ៌ខ្មៅ មានភ្ជាប់រូបព្រះសង្ការពណ៌ប្រាក់ ទំហំកម្ពស់៧៨ម.ម. ទទឹង៦៨ម.ម. ផ្នែកខាងក្រោមនៃជើងម្ចុក និងក្រោមព្រះសង្ការមានខ្សែធ្វាក់វិញខ្នាតតូចពណ៌ប្រាក់ពីលើជើងម្ចុកពណ៌ខ្មៅ ព្រមទាំងនៅខាងចុងខ្សែធ្វាក់វិញទាំងសងខាងមានភ្ជាប់ឡេវរូបព្រះសង្ការពណ៌ប្រាក់ ខាងក្រោមខ្សែធ្វាក់វិញផ្នែកខាងមុខមានក្បាំងពណ៌ខ្មៅ នៅលើចុងក្បាំងមានដេរភ្ជាប់ខ្សែធ្វាក់វិញពណ៌ប្រាក់ទំហំ៥ម.ម.។

ម្ចុកទាំងប្រាំថ្នាក់ខាងលើរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី១៣។

**មាត្រា៩ ._**

ឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងម្ចុក ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបានផ្តល់ជូនមន្ត្រីម្នាក់ៗចំនួន២(ពីរ)សម្រាប់ នូវឯកសណ្ឋាន សម្រាប់ប្រើប្រាស់ក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា១០ ._**

មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ ម្ចុក និងត្រូវមានលិខិតបញ្ជាបេសកកម្ម នៅពេលប្រតិបត្តិការអនុវត្តច្បាប់។ ក្នុងពិធីប្រជុំឬពិធីការផ្សេងៗទៀត បើចាំបាច់ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងម្ចុក ដូចមានចែងក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៣

## ទោសប្បញ្ញត្តិ

**មាត្រា១១ ._**

ជនណាក្លែងបន្លំ ដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសក្តិ សញ្ញាសម្គាល់ និងម្ចុក របស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។/.

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

**នៃអនុក្រឹត្យលេខ១៧៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៦**

**ស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**



ឯកសណ្ឋានអាវដៃវែង ឯកសណ្ឋានអាវដៃខ្លី

**ឧបសម្ព័ន្ធទី២**

**នៃអនុក្រឹត្យលេខ១៨៧ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**



**ឧបសម្ព័ន្ធទី៣**

**នៃអនុក្រឹត្យលេខ ១៧៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសម្គាល់សម្រាប់ព្យួរលើហោប៉ៅអាវរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**






**ឧបសម្ព័ន្ធទី៤**

**នៃអនុក្រឹត្យលេខ..១៨៤ អនក្រ.បក.... ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសម្រាប់ពាក់ជាប់ចុងកអាវរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**




សញ្ញាសម្រាប់ពាក់ជាប់ចុងកអាវពណ៌មាស




សញ្ញាសម្រាប់ពាក់ជាប់ចុងកអាវពណ៌ប្រាក់

**ឧបសម្ព័ន្ធទី៥**

**នៃអនុក្រឹត្យលេខ១៨១.អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូស្លាកសម្គាល់ឈ្មោះរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**




ស្លាកសម្គាល់ឈ្មោះពណ៌មាស




ស្លាកសម្គាល់ឈ្មោះពណ៌ប្រាក់

**ឧបសម្ព័ន្ធទី៦**

**នៃអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់ថ្នាក់អគ្គាធិការនិងអគ្គនាយក**



## ឧបសម្ព័ន្ធទី៧

### នៃអនុក្រឹត្យលេខ.១៨៧៦ អនក្រ.បក..... ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦
### ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍

### គំរូសញ្ញាសក្តិសម្រាប់ថ្នាក់អគ្គាធិការរងនិងអគ្គនាយករង



**ឧបសម្ព័ន្ធទី៨**

**នៃអនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់ថ្នាក់អធិការនិងប្រធាននាយកដ្ឋាន**



**ឧបសម្ព័ន្ធទី៩**

**នៃអនុក្រឹត្យលេខ១៤៥ អនក្រ.បក...... ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់ថ្នាក់អធិការរង អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីរប.ទ រាជធានី/ខេត្ត**



**ឧបសម្ព័ន្ធទី១០**

**នៃអនុក្រឹត្យលេខ ១៧៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាល**

**និងអនុប្រធានមន្ទីរប.ទ រាជធានី/ខេត្ត**




x

**ឧបសម្ព័ន្ធទី១១**

**នៃអនុក្រឹត្យលេខ១៨៦ អនក្រ.បក..... ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាលនិងប្រធានការិយាល័យប.ទ រាជធានី/ខេត្ត**



**ឧបសម្ព័ន្ធទី១២**

**នៃអនុក្រឹត្យលេខ១៧៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦**

**ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍**

**គំរូសញ្ញាសក្តិសម្រាប់មន្ត្រី**



## ឧបសម្ព័ន្ធទី១៣

### នៃអនុក្រឹត្យលេខ ១៧៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៦

### ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍

### គំរូមួកកាស្កេត

| | |
|---|---|
|  | ថ្នាក់អគ្គាធិការនិងអគ្គនាយក |
|  | ថ្នាក់អគ្គាធិការរងនិងអគ្គនាយករង |
|  | ថ្នាក់អធិការ ប្រធាននាយកដ្ឋាន អធិការរង អនុប្រធាននាយកដ្ឋាន និងប្រធានមន្ទីរប.ទ រាជធានី/ខេត្ត |
|  | ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាល អនុប្រធានមន្ទីរប.ទ រាជធានី/ខេត្ត អនុប្រធានការិយាល័យថ្នាក់កណ្តាល និងប្រធានការិយាល័យប.ទ រាជធានី/ខេត្ត |
|  | ថ្នាក់មន្ត្រី |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ១៨៣ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតតំបន់អភិរក្សទឹកសាបបឹងព្រែកទប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- លិខិតលេខ ២៣៧ សជណ.ឧស ចុះថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតតំបន់អភិរក្សទឹកសាបបឹងព្រែកទប់ ដែលមានផ្ទៃដីទំហំ ១៦,៣ ហិកតា (ដប់ប្រាំមួយហិកតានិងសាមសិបអារ) ស្ថិតក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា( Datum: WGS1984 )ដូចខាងក្រោម៖

| និយាមកាគោល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ID | X | Y | ID | X | Y | ID | X | Y |
| 1 | 335575 | 1173984 | 12 | 335954 | 1174231 | 23 | 336148 | 1174056 |
| 2 | 335540 | 1174006 | 13 | 335996 | 1174208 | 24 | 336121 | 1174087 |
| 3 | 335506 | 1174040 | 14 | 336055 | 1174147 | 25 | 336031 | 1174074 |
| 4 | 335544 | 1174092 | 15 | 336222 | 1174156 | 26 | 335956 | 1174110 |
| 5 | 335570 | 1174091 | 16 | 336344 | 1174197 | 27 | 335921 | 1174139 |
| 6 | 335638 | 1174161 | 17 | 336390 | 1174241 | 28 | 335881 | 1174129 |
| 7 | 335716 | 1174312 | 18 | 336442 | 1174205 | 29 | 335820 | 1174143 |
| 8 | 335803 | 1174537 | 19 | 336343 | 1174072 | 30 | 335768 | 1174111 |
| 9 | 335835 | 1174525 | 20 | 336288 | 1174023 | 31 | 335733 | 1174044 |
| 10 | 335868 | 1174491 | 21 | 336193 | 1174013 | 32 | 335705 | 1174001 |
| 11 | 335933 | 1174268 | 22 | 336168 | 1174046 | 33 | 335773 | 1173890 |
| | | | | | | 34 | 335752 | 1173865 |

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាការថែរក្សា និងការពារសោភ័ណភាពធម្មជាតិ វប្បធម៌ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះក្នុងតំបន់អភិរក្សទឹកសាបបឹងព្រែកទប់
- ផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋានក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣** .-

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់អភិរក្សទឹកសាបបឹងព្រែកទប់ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលដែនដីខេត្តព្រះសីហនុ ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

**មាត្រា៤** .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ផែនទីតំបន់អភិរក្សទឹកសាបបឹងព្រែកទប់ ស្ថិតក្នុងខេត្តព្រះសីហនុ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ១៥៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ .



| និយាមការ | | |
|---|---|---|
| Id | X | Y |
| 1 | 335575 | 1173984 |
| 2 | 335540 | 1174006 |
| 3 | 335506 | 1174040 |
| 4 | 335544 | 1174092 |
| 5 | 335570 | 1174091 |
| 6 | 335638 | 1174161 |
| 7 | 335716 | 1174312 |
| 8 | 335803 | 1174537 |
| 9 | 335835 | 1174525 |
| 10 | 335868 | 1174491 |
| 11 | 335933 | 1174268 |
| 12 | 335954 | 1174231 |
| 13 | 335996 | 1174208 |
| 14 | 336055 | 1174147 |
| 15 | 336222 | 1174156 |
| 16 | 336344 | 1174197 |
| 17 | 336390 | 1174241 |
| 18 | 336442 | 1174205 |
| 19 | 336343 | 1174072 |
| 20 | 336288 | 1174023 |
| 21 | 336193 | 1174013 |
| 22 | 336168 | 1174046 |
| 23 | 336148 | 1174056 |
| 24 | 336121 | 1174087 |
| 25 | 336031 | 1174074 |
| 26 | 335956 | 1174110 |
| 27 | 335921 | 1174139 |
| 28 | 335881 | 1174129 |
| 29 | 335820 | 1174143 |
| 30 | 335768 | 1174111 |
| 31 | 335733 | 1174044 |
| 32 | 335705 | 1174001 |
| 33 | 335773 | 1173890 |
| 34 | 335752 | 1173865 |

- ផ្ទៃតំបន់អភិរក្សទឹកសាបបឹងព្រែកទប់ ទំហំសរុប ១៦,៣ ហិកតា




សញ្ញាសម្គាល់

- ● ចំណុចគោល
- ▭ ព្រំប្រទល់តំបន់អភិរក្សទឹកសាបព្រែកទប់

0 100 200 Meters

Map Coordinate System:
Unit: meter
System: UTM, Zone 48
Datum: WGS 1984

ព្រះសីហនុ ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៦
អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ

យន្ត. មីន

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦
រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥២៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីអប់រំ ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ ចំនួន១១៣០រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

| | | | | | | |
|---|---|---|---|---|---|---|
| ១ | លោក | ទី | សែត | ប្រធានមន្ទីរ | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ២ | លោក | ថុក | ប៊ុនធឿន | អនុប្រធានមន្ទីរ | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ៣ | លោកស្រី | គង | រចនា | អនុការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ៤ | លោក | អ៊ឹម | អៀត | មន្ត្រីការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ៥ | លោក | ហុក | ធីរៈ | មន្ត្រីការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ៦ | លោក | តឹង | សីហា | មន្ត្រីការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ៧ | លោក | ឆន | ឈាង | អនុ.ការិ | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ៨ | លោក | ឆៀង | វិសាល | អនុ.ការិ | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ៩ | លោក | អ៊ុច | ជឹម | មន្ត្រីការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ១០ | លោក | ប៉ូ | វណ្ណារិទ្ធិ | ប្រធានការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ១១ | លោក | មាស | សារ៉ាត់ | មន្ត្រីការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ១២ | លោក | ភួង | មុនី | ប្រធានការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ១៣ | លោកស្រី | សៀ | គីមណា | អនុ.ការិ | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ១៤ | លោក | ម៉ក់ | ចំណាប់ | មន្ត្រីការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ១៥ | លោកស្រី | ផាំ | សុធារី | មន្ត្រីការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ១៦ | លោក | ហ៊ុង | គីមហឿន | ប្រធានការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ១៧ | លោកស្រី | ឆឹង | ម៉ារ៉ាឌី | មន្ត្រីការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |

| | | | | | | |
|---|---|---|---|---|---|---|
| ១៨ | លោកស្រី | អ៊ុំ | ចិន្តា | អនុ.ការិ | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ១៩ | លោក | យាន | ប៊ី | ប្រធានការិ. | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ២០ | លោក | ហុង | ប៊ុនថន | មន្ត្រី | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ២១ | លោក | នូ | សំណាង | អនុ.ការិ | មន្ទីរ. អយកខេត្ត | បាត់ដំបង |
| ២២ | លោក | ខ្វៃ | ម៉ូច | ពិសោធន៍ | វិទ្យាល័យព្រះមុនីវង្ស | បាត់ដំបង |
| ២៣ | លោក | ពៅ | វដ្ឋា | ស.យុវជន | វិទ្យាល័យព្រះមុនីវង្ស | បាត់ដំបង |
| ២៤ | លោកស្រី | សោម | អច្ឆរា | គ្រូបង្រៀន | អនុវិទ្យាល័យអនុវត្តន៍ | បាត់ដំបង |
| ២៥ | លោកស្រី | ស៊ិន | ជីពុន | គ្រូបង្រៀន | អនុវិទ្យាល័យអនុវត្តន៍ | បាត់ដំបង |
| ២៦ | លោក | អ៊ុំម | សុធី | អនុ.ការិ | មជ្ឈមណ្ឌលគរុ .ភូមិភាគ | បាត់ដំបង |
| ២៧ | លោក | ឈាន | ហាង | គ្រូឧទ្ទេស | មជ្ឈមណ្ឌលគរុ .ភូមិភាគ | បាត់ដំបង |
| ២៨ | លោកស្រី | អ៊ិត | ចាន់ធឿន | គ្រូឧទ្ទេស | មជ្ឈមណ្ឌលគរុ .ភូមិភាគ | បាត់ដំបង |
| ២៩ | លោក | ម៉ុក | ថេង | ប្រធានការិ. | សាលាគរុ.និងវិក្រឹតការ ខេត្ត | បាត់ដំបង |
| ៣០ | លោក | លី | វណ្ណា | គ្រូបង្រៀន | វិទ្យាល័យនេតយ៉ង់ | បាត់ដំបង |
| ៣១ | លោកស្រី | អៀម | ម៉ាច | គ្រូបង្រៀន | វិទ្យាល័យនេតយ៉ង់ | បាត់ដំបង |
| ៣២ | លោកស្រី | ឈឹម | ផលវឌ្ឍនា | គ្រូបង្រៀន | វិទ្យាល័យនេតយ៉ង់ | បាត់ដំបង |
| ៣៣ | លោកស្រី | ជិន | ផាន់ឈាង | គ្រូបង្រៀន | វិទ្យាល័យសម្តេចឪ | បាត់ដំបង |
| ៣៤ | លោកស្រី | សួស | សោភា | គ្រូបង្រៀន | វិទ្យាល័យសម្តេចឪ | បាត់ដំបង |
| ៣៥ | លោក | ឈឹម | ប៊ុនលី | គ្រូបង្រៀន | សាលាភាសាឃ្សូអ័រ | បាត់ដំបង |
| ៣៦ | លោក | គង់ | ស៊ីថា | មន្ត្រីការិ. | ការិយាល័យអយក. | ក្រុងបាត់ដំបង |
| ៣៧ | លោក | គង់ | សម្ផស្ស | មន្ត្រីការិ. | ការិយាល័យអយក. | ក្រុងបាត់ដំបង |
| ៣៨ | លោក | ជាង | លាប | មន្ត្រីការិ. | ការិយាល័យអយក. | ក្រុងបាត់ដំបង |
| ៣៩ | លោកស្រី | ម៉ែត | សុតិន | មន្ត្រីការិ. | ការិយាល័យអយក. | ក្រុងបាត់ដំបង |
| ៤០ | លោកស្រី | ញើ | គំសត់ | គ្រូបង្រៀន | អនុវិទ្យាល័យសោហឺ | ក្រុងបាត់ដំបង |
| ៤១ | លោក | កែ | សុភឿន | គ្រូបង្រៀន | អនុវិទ្យាល័យសោហឺ | ក្រុងបាត់ដំបង |
| ៤២ | លោក | ឡាយ | គង់ហ៊ាន | គ្រូបង្រៀន | អនុវិទ្យាល័យវត្តដំរីស | ក្រុងបាត់ដំបង |
| ៤៣ | លោក | ឌិត | ស៊ីរ៉ាក់ធុន | គ្រូបង្រៀន | អនុវិទ្យាល័យចំការសំរោង | ក្រុងបាត់ដំបង |
| ៤៤ | លោកស្រី | ឌុច | សុគន្ធា | នាយិការង | អនុវិទ្យាល័យវត្តគរ | ក្រុងបាត់ដំបង |
| ៤៥ | លោកស្រី | ហឿន | សុភា | គ្រូបង្រៀន | អនុវិទ្យាល័យអូម៉ាល់ | ក្រុងបាត់ដំបង |
| ៤៦ | លោកស្រី | ខន | សាធុន | គ្រូបង្រៀន | វិទ្យាល័យក្អលដូនទាវ | ក្រុងបាត់ដំបង |
| ៤៧ | លោកស្រី | មាស | សាលីវណ្ណា | គ្រូបង្រៀន | វិទ្យាល័យហ្វាពន្លឺសិល្ប: | ក្រុងបាត់ដំបង |
| ៤៨ | លោកស្រី | លឹម | គន្ធា | គ្រូបង្រៀន | បឋមសិក្សា ព្រែកោង | ក្រុងបាត់ដំបង |
| ៤៩ | លោកស្រី | វណ្ណា | សុផាន់ | នាយិកា | បឋមសិក្សា អង់ | ក្រុងបាត់ដំបង |
| ៥០ | លោក | ថ៊ាន | សារេត | នាយក | បឋមសិក្សា ទួលតាឯក | ក្រុងបាត់ដំបង |
| ៥១ | លោកស្រី | ហ៊ិត | ច័ន្ទស៊ី | គ្រូបង្រៀន | បឋមសិក្សា សម្តេចជាស៊ីម | ក្រុងបាត់ដំបង |
| ៥២ | លោក | យ៉ាន | ស៊ុនតែន | នាយករង | បឋមសិក្សា ២ធ្នូ | ក្រុងបាត់ដំបង |
| ៥៣ | លោក | យ៉ា | បុណា | គ្រូបង្រៀន | បឋមសិក្សា សម្តេចជាស៊ីម | ក្រុងបាត់ដំបង |
| ៥៤ | លោកស្រី | ហ៊ុំង | សុផា | គ្រូបង្រៀន | បឋមសិក្សា ២ធ្នូ | ក្រុងបាត់ដំបង |
| ៥៥ | លោក | ស | ប៊ុនរិទ្ធ | គ្រូបង្រៀន | បឋមសិក្សា ២ធ្នូ | ក្រុងបាត់ដំបង |

| | | | | | | |
|---|---|---|---|---|---|---|
| ៥៦ | លោកស្រី | ណាប់ | ដាទី | គ្រូបង្រៀន | បឋមសិក្សា វត្តកំផែង | ក្រុងបាត់ដំបង |
| ៥៧ | លោក | សោ | ធី | នាយក | បឋមសិក្សា បឹងរាំង | ក្រុងបាត់ដំបង |
| ៥៨ | លោក | ឃិត | សារិទ្ធ | នាយក | បឋមសិក្សា សាលាបាឡាត់ | ក្រុងបាត់ដំបង |
| ៥៩ | លោកស្រី | អៀម | ដល្លីកា | នាយិកា | បឋមសិក្សា ទ្រាបក្រសាំង | ក្រុងបាត់ដំបង |
| ៦០ | លោក | ណុប | ប្រុស | ប្រធានការិ. | ការិយាល័យ.អយក | ស្រុករតនមណ្ឌល |
| ៦១ | លោក | តាន់ | ឫទ្ធី | នាយក | អនុវិ.រតនមណ្ឌល | ស្រុករតនមណ្ឌល |
| ៦២ | លោក | ធេព | វណ្ណា | នាយក | អនុវិ.ហ៊ុនសែន ត្រែង | ស្រុករតនមណ្ឌល |
| ៦៣ | លោក | នន់ | វណ្ណៈ | នាយក | បឋមសិក្សា ព្រៃអំពរ | ស្រុករតនមណ្ឌល |
| ៦៤ | លោក | កែម | គីមហាន | នាយក | អនុវិទ្យាល័យផ្លូវមាស | ស្រុករតនមណ្ឌល |
| ៦៥ | លោក | ញ៉ែម | សម្បត្តិ | មន្ត្រីការិ. | ការិយាល័យ.អយក | ស្រុកបវេល |
| ៦៦ | លោក | ម៉ង់ | មឿន | មន្ត្រីការិ. | ការិយាល័យ.អយក | ស្រុកបវេល |
| ៦៧ | លោក | សារិត | ដាន់ | មន្ត្រីការិ. | ការិយាល័យ.អយក | ស្រុកបវេល |
| ៦៨ | លោក | សោ | គំណា | នាយក | វិទ្យាល័យល្វា | ស្រុកបវេល |
| ៦៩ | លោកស្រី | ឈុន | ចាន់រ៉េយ | គ្រូបង្រៀន | វិទ្យាល័យបវេល | ស្រុកបវេល |
| ៧០ | លោកស្រី | ចៅ | ឈុនឡៃ | គ្រូបង្រៀន | វិទ្យាល័យបវេល | ស្រុកបវេល |
| ៧១ | លោក | ចា | សាវឿន | នាយក | អនុវិ.អំពិលប្រាំដើម | ស្រុកបវេល |
| ៧២ | លោក | ជូ | សុគន្ធារី | នាយិកា | បឋមសិក្សា ក្តុលតាហែន | ស្រុកបវេល |
| ៧៣ | លោក | គៀប | សេរីវុធ | នាយក | អនុវិទ្យាល័យខ្នាចរមាស | ស្រុកបវេល |
| ៧៤ | លោក | ស៊ិយ | សុភាព | នាយករង | វិទ្យាល័យសំពៅលូន | ស្រុកសំពៅលូន |
| ៧៥ | លោក | គី | គៀង | នាយក | អនុវិទ្យាល័យអូរចំណិប | ស្រុកសំពៅលូន |
| ៧៦ | លោក | ហែម | ស៊ីផា | នាយក | បឋមសិក្សា សន្តិភាព | ស្រុកសំពៅលូន |
| ៧៧ | លោក | ជួន | សារ៉ាត់ | មន្ត្រីការិ. | ការិយាល័យអយកស | ស្រុកភ្នំព្រឹក |
| ៧៨ | លោក | នៅ | វាសនា | នាយក | បឋមសិក្សា ដំណាក់ក្សាន្ត | ស្រុកភ្នំព្រឹក |
| ៧៩ | លោក | មាស | ម៉ឺន | នាយករង | បឋមសិក្សា ពេជ្រចិន្តា | ស្រុកភ្នំព្រឹក |
| ៨០ | លោក | ហ៊ិន | សុផល | មន្ត្រីការិ. | ការិយាល័យអយកស. | ស្រុកភ្នំព្រឹក |
| ៨១ | លោក | ទឿន | ខុល | នាយករង | វិទ្យាល័យមោងឫស្សី | ស្រុកមោងឫស្សី |
| ៨២ | លោក | ស៊ុន | គីមសាន | នាយក | បឋមសិក្សា យីនមាន | ស្រុកមោងឫស្សី |
